**Declassified to Public**
**16 August 2018**

លេខ៖ D355/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 09 / 2017
ម៉ោង (Time/Heure): 11:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧

ភាសា ៖ អង់គ្លេស & ខ្មែរ

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បញ្ចូលឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុច
Richard ROGERS
Göran SLUITER

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES NZEPA
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ មេធាវីការពារក្តី អោ អាន ("មេធាវីការពារក្តី") បានដាក់*សំណើបន្ទាន់សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា* ("សំណើ")[1]។

៣. នៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញា បានជូនដំណឹង ស.ច.ស ថា សហព្រះរាជអាជ្ញា មិនមានបំណងឆ្លើយតបទៅនឹងសំណើនេះទេ[2]។

## II. សារណា

៤. យើងយោងលើសំណើ សម្រាប់ព័ត៌មានលម្អិតអំពីទឡ្ហីករណ៍នានា។ ជាគោលការណ៍ មេធាវីការពារក្តី ផ្តល់ទឡ្ហីករណ៍ថា៖

ក. ដោយពិនិត្យឃើញថា សហព្រះរាជអាជ្ញាជាតិ ("ស.ព.ជ") និងសហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់ដីកាសន្និដ្ឋានស្ថាពរផ្ទុយគ្នា ជាពិសេស ស.ព.ជ មានយោបល់ខ្វែងជាចម្បងលើបញ្ហាយុត្តាធិការបុគ្គលនោះ[3] ទើប មេធាវីការពារក្តី ចាំបាច់ត្រូវចូលពិនិត្យមើលឯកសារទាំងអស់ ដែលជាមូលដ្ឋាននៃកិច្ចដំណើរការនីតិវិធីខ្វែងយោបល់ យោងតាមវិធានផ្ទៃក្នុង ៧១ រវាងសហព្រះរាជអាជ្ញា ដើម្បីធ្វើជាព័ត៌មានសម្រាប់ការឆ្លើយតបរបស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពរនានារបស់សហព្រះរាជអាជ្ញា[4]។

---

[1]សំណុំរឿង ០០៤/២ ឯកសារ D355 *សំណើបន្ទាន់សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា* ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ("សំណើ")។

[2]សំណុំរឿង ០០៤/២ ឯកសារ D355/1.1 *អ៊ីមែលពី* *Travis Michae Farr* *ផ្ញើជូន* *Filippo de Minicis* ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៧។

[3]សំណើ កថាខណ្ឌ ៣៦, ៣៧។

[4]សំណើ កថាខណ្ឌ ៤១(ក)។

ខ. មេធាវីការពារក្ដី ក៏ចាំបាច់ត្រូវចូលពិនិត្យមើលឯកសារទាំងស្រុង និងគ្មានការកោសលុបនៃនីតិវិធីខ្វែងយោបល់ដែលពាក់ព័ន្ធនឹង អោ អាន នៅចំពោះមុខអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ផងដែរ[5]។

គ. មេធាវីការពារក្ដី ចាំបាច់ត្រូវចូលពិនិត្យមើលឯកសារ ដីកា និងដីកាសម្រេចណាដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ណាមួយរវាង ស.ច.ស អំពីបញ្ហាយុត្តាធិការបុគ្គលលើ អោ អាន[6]។

៥. មេធាវីការពារក្ដី អះអាងថា ខ្លួនចាំបាច់ត្រូវមានលទ្ធភាពដូចខាងលើនេះ ដើម្បីប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់កូនក្ដី និងដើម្បីទប់ទល់ជាមួយនឹងអសមភាពនៃមធ្យោបាយតទល់ក្ដី ពីព្រោះថា ស.ព.ជ និង ស.ព.អ បានដឹងអំពីការយល់ឃើញរបស់ខ្លួនទៅវិញទៅមក ហើយមេធាវីការពារក្ដី ស្ថិតនៅក្នុងជំហរចាញ់ប្រៀបផ្នែកឯកសារ ដោយសារខ្វះការយល់ដឹងទាំងស្រុងអំពីប្រភេទឯកសារទាំងបីខាងលើនេះ[7]។

## II. ពិភាក្សា

៦. សំណើ មិនមានមូលដ្ឋានទេ។

៧. នីតិវិធីខ្វែងយោបល់ណាមួយរវាងសហព្រះរាជអាជ្ញា គឺជាការសម្ងាត់ ហើយឯកសារដែលជាមូលដ្ឋាននៃការខ្វែងយោបល់បែបនេះមិនមែនជាផ្នែកមួយនៃសំណុំរឿងទេ។ ស.ច.ស ក៏មិនអាចចូលពិនិត្យមើលឯកសារបែបនេះបានដែរ។ ស.ច.ស ក៏មិនមានអំណាចបង្គាប់ឱ្យ ស.ព.ជ ឬ ស.ព.អ ដាក់បង្ហាញករណីខ្វែងយោបល់ចូលក្នុងសំណុំរឿងដែរ ប្រសិនបើសហព្រះរាជអាជ្ញាមិនបានសម្រេចដាក់បង្ហាញទេ។

៨. ករណីដូចគ្នានេះក៏អនុវត្តផងដែរចំពោះឯកសារណាមួយដែលមាននៅក្នុងកិច្ចដំណើរការនីតិវិធីខ្វែងយោបល់នៅចំពោះមុខ អ.ប.ជ។ បន្ទាប់ពីពិគ្រោះយោបល់ជាមួយនឹងសហព្រះរាជអាជ្ញារួចមក អ.ប.ជ គឺជាអ្នកសម្រេចថាតើខ្លួនចង់បញ្ចេញឯកសារណាមួយដែរឬអត់ពីកិច្ចដំណើរការនីតិវិធីទាំងនោះ។

---

[5]សំណើ កថាខណ្ឌ ៤១(ខ)។

[6]សំណើ កថាខណ្ឌ ៤១(គ)។

[7]សំណើ កថាខណ្ឌ ៣៨។



CO-INVESTIGATING ... ECCC

៩. ការខ្វែងយោបល់រវាង ស.ច.ស គឺជាការសម្ងាត់ ហើយយើងមិនឃើញមានសំអាងហេតុណាដែលត្រូវបញ្ចេញព័ត៌មានអ្វីឡើយ ក្រៅពីអង្គហេតុដែលថា មានករណីខ្វែងយោបល់ (សូមមើល កថាខណ្ឌ ១ ខាងលើ) ជាអ្វីដែលយើងមិនចាំបាច់ត្រូវធ្វើឡើងឡើយយោងតាមវិធានផ្ទៃក្នុង។

១០. យើងមិនឃើញមានសំអាងហេតុដែលមេធាវីការពារក្ដី ចាំបាច់ត្រូវចូលពិនិត្យមើលករណីខ្វែងយោបល់របស់យើង ដើម្បីឆ្លើយតបទៅនឹងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទេ។ សហព្រះរាជអាជ្ញា ក៏មិនអាចចូលពិនិត្យមើលឯកសារទាំងនេះបានដែរ ហេតុនេះ សហព្រះរាជអាជ្ញា មិនអាចយកឯកសារទាំងនេះធ្វើជាមូលដ្ឋានសម្រាប់ដីកាសន្និដ្ឋានរបស់ខ្លួនបានឡើយ។

១១. យើងនឹងពិចារណាអំពីខ្លឹមសារនៃដីកាដំណោះស្រាយ តែពេលបន្ទាប់ពីបានទទួលសេចក្ដីសន្និដ្ឋានពីសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដីតែប៉ុណ្ណោះ ហេតុនេះ តាមទ្រឹស្ដី ករណីខ្វែងយោបល់ណាមួយនាបច្ចុប្បន្ននេះអាចលែងជាការចាំបាច់។

១២. វាក៏មិនមានការចាញ់ប្រៀបខាងឯកសារដែរសម្រាប់មេធាវីការពារក្ដី។ ស.ច.ស មិនជាប់កាតព្វកិច្ច ត្រូវធ្វើតាមសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទេ រាប់បញ្ចូលទាំងសេចក្ដីសន្និដ្ឋានលើយុត្តាធិការបុគ្គលផងដែរ។ ស.ព.ជ ស្នើសុំឲ្យលើកលែងការចោទប្រកាន់ ជាករណីដែលមិនមានការតវ៉ាពីមេធាវីការពារក្ដីទេ។ ហេតុនេះ មេធាវីការពារក្ដី ត្រូវការពារក្ដីប្រឆាំងតែសំណើរបស់ ស.ព.អ ដែលសុំឲ្យចោទប្រកាន់បញ្ជូនទៅជំនុំជម្រះតែប៉ុណ្ណោះ ហើយការងារបែបនេះ រួមមានការវាយតម្លៃផ្ទាល់ខ្លួនរបស់មេធាវីការពារក្ដីលើភ័ស្តុតាង រាប់បញ្ចូលទាំងបញ្ហាយុត្តាធិការផងដែរ គឺដូចគ្នានឹងអ្វីដែលមេធាវីការពារក្ដី ត្រូវធ្វើដើម្បីជំទាស់ជាមួយនឹងសំណើរួមសុំឲ្យចោទប្រកាន់បញ្ជូនទៅជំនុំជម្រះដែរ។ យើង បានបង្ហាញការយល់ឃើញរបស់យើងរួចហើយអំពីលក្ខណវិនិច្ឆ័យទូទៅពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)នៅក្នុងសំណុំរឿង ០០៤/១[៩]។

១៣. យើងគិតទុកជាមុនថា សំណើនេះ ប្រហែលជាធ្វើឡើងក្នុងគោលបំណងដើម្បីរៀបចំវិធានការដែលត្រូវអនុវត្តជាបន្តបន្ទាប់ទៀត ប្រសិនបើពិនិត្យមើលទស្សនៈរបស់មេធាវី ហើយដូចគ្នាភាគច្រើន នឹងសំណើដែលមេធាវីការពារក្ដីបានដាក់រួចហើយ ចំពោះករណីដីកាសន្និដ្ឋានស្ដាពរ

---

[៩] សំណុំរឿង ០០៤/១ ឯកសារ D308/3 *ដីកាដំណោះស្រាយ (សំអាងហេតុ)* ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។

01531374



ដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នារបស់សហព្រះរាជអាជ្ញា[9] វាអាចនឹងមានសំណើសុំការបញ្ជាក់បំភ្លឺ ពីយើងអំពីបញ្ហាចោទថាតើ ច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក អនុញ្ញាតឱ្យចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាដែរឬអត់។

១៤. ដើម្បីកុំឱ្យមានការតវ៉ាអំពីចំណុចនេះនាពេលអនាគត និងដើម្បីចំណេញពេលវេលាសម្រាប់ភាគីទាំងអស់ យើងសូមបញ្ជាក់ថា យើងពិចារណាចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និង ផ្ទុយគ្នា[10] ដូចដែលបានអនុញ្ញាតជាទូទៅតាមច្បាប់ជាធរមាន ជាពិសេសតាមសំអាងហេតុដែលយើងបានរកឃើញពាក់ព័ន្ធនឹងដីកាសន្និដ្ឋានស្ថាពរផ្ទុយគ្នា[11]។ យើងក៏បានបង្ហាញជាតម្រុយជាសាធារណៈផងដែរអំពីលទ្ធភាពនេះនៅក្នុងសំណៅចុងក្រោយបង្អស់នៃរបាយការណ៍បញ្ចប់ការងារប្រចាំត្រីមាស[12]។

១៥. យើងដឹងអំពីបញ្ហាដែលអាចនឹងកើតឡើងនៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍។ វិធានផ្ទៃក្នុង ៧៧ (១៣) គ្រាន់តែចែងអំពីសេណារីយ៉ូដែលមានដីកាលើកលែងការចោទប្រកាន់ ឬ ក៏មានដីកាចោទប្រកាន់បញ្ជូនទៅជំនុំជម្រះរួមគ្នា ប៉ុន្តែមិនមានចែងអំពីដីកាដំណោះស្រាយ ដាច់ដោយឡែកពីគ្នាទេ។ យ៉ាងណាក៏ដោយ មិនមានយុត្តិកម្មទេ ប្រសិនបើអះអាងថា មានការហាមឃាត់មិនឱ្យមានដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា។ ផ្ទុយមកវិញ ជាឧទាហរណ៍ នៅក្នុងសាលដីការបស់ខ្លួននៅក្នុងសំណុំរឿង ០០១[13] អង្គជំនុំជម្រះតុលាការកំពូល បានទទួលស្គាល់យ៉ាងច្បាស់អំពីសេណារីយ៉ូដែល ស.ច.ស មានសំអាងហេតុខ្វែងយោបល់អំពីយុត្តាធិការបុគ្គល ហើយក៏ទទួលស្គាល់យ៉ាងច្បាស់ថា នៅក្នុងបរិបទនៃនីតិវិធីខ្វែងយោបល់ កិច្ចស៊ើបសួរត្រូវបន្តទៅមុខ។

១៦. យើងយល់ឃើញថា ដំណាក់កាលស៊ើបសួរ ចប់នៅពេលចុងក្រោយបំផុត គឺនៅពេលដែល អ.ប.ជ ចេញសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។ ប្រសិនបើ

---

[9]សំណុំរឿង ០០៤/២ ឯកសារ D353 *សំណើសុំការបញ្ជាក់បំភ្លឺ* ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧។

[10]តាមទ្រឹស្ដី នេះក៏រាប់បញ្ចូលទាំងដីកាបញ្ជូនទៅជំនុំជម្រះចំនួនពីរដែលមានខ្លឹមសារផ្សេងគ្នាដែរ។

[11]សំណុំរឿង ០០៤/២ ឯកសារ D353/1 *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ* ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៧។

[12] ផែនការបញ្ចប់ការងារ អ.វ.ត.ក លើកទី ១៣ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧ កថាខណ្ឌ ២៣ កំណត់សម្គាល់ទី ១២ អាចរកបានតាមរយៈ https://www.eccc.gov.kh/en/eccc-completion-plan-revision-13។

[13]សំណុំរឿង ០០១ ឯកសារ F28 *សាលដីកា* អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ៦៥។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C *

01531375



អ.ប.ជ មិនមានសម្លេងភាគច្រើនគាំទ្រដីកាដំណោះស្រាយណាមួយក្នុងចំណោមដីកាដំណោះស្រាយទាំងពីរទេនោះ ដីកាដំណោះស្រាយទាំងពីរត្រូវតម្កល់ទុកជាបានការ តាមការអនុវត្តវិធានផ្ទៃក្នុង ៧៧(១៣) ប៉ុន្តែ តាមការយល់ឃើញរបស់យើង មិនមាន*កិច្ចស៊ើបសួរក្នុងន័យចង្អៀត* ថែមទៀតដែលអាចបន្តទៅមុខទេ។ យ៉ាងណាក៏ដោយ ដំណោះស្រាយសម្រាប់សេណារីយ៉ូបែបនេះគឺស្ថិតនៅក្នុងយុត្តាធិការទាំងស្រុងរបស់ អ.ប.ជ។

១៧. យើងសន្និដ្ឋានថា ដីកាសម្រេចនេះនឹងមានប្រយោជន៍ផងដែរសម្រាប់ភាគីសំណុំរឿង 00៤។

១៨. ស.ច.ស.អ នឹងចេញសេចក្តីណែនាំដាច់ដោយឡែក អំពីការដាក់សំណៅមួយច្បាប់នៃដីកាសម្រេចនេះចូលក្នុងសំណុំរឿង 00៣។

**តាមសំអាងហេតុខាងលើ យើង**[14]៖

១៩. **បដិសេធ** សំណើ។

២០. **បង្គាប់ឲ្យ** ក្រឡាបញ្ជី ដាក់សំណៅសម្ងាត់មួយច្បាប់នៃដីកាសម្រេចនេះចូលក្នុងសំណុំរឿង 00៤។

ភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juge d'instruction

**ចៅក្រម យូ ប៊ុនឡេង** **ចៅក្រម Michael BOHLANDER**

[14] ចៅក្រមទាំងពីរចុះហត្ថលេខាលើដីកាសម្រេចនេះរួមគ្នា ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតជាតិ សូមរំឭកថា គាត់មិនទទួលស្គាល់ ឬ ក៏ទទួលយកថាមានសុពលភាពទេចំពោះឯកសារណាដែលបានបង្កើត និង/ឬដាក់ដោយអតីតសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Kasper-Ansermet ហេតុនេះ ការដាក់លេខឯកសារសំណុំរឿង គួរដាក់លេខបន្តពីឯកសារចុងក្រោយដែលបានដាក់មុនពេលអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Blunk បានលាលែងតំណែង ហើយ មិនរាប់បញ្ចូលឯកសារណាមួយដែលបានដាក់ដោយចៅក្រម Kasper-Ansermet ឡើយ។